# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២ និង
# លើកទិសដៅការងារឆ្នាំ ២០២៣ របស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ

## សេចក្តីផ្តើម

ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា ព្រមទាំងលើកកម្ពស់សុខភាពសាធារណៈ និងស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ និងជនងាយរងគ្រោះ នាយកដ្ឋានបានខិតខំប្រឹងប្រែងអនុវត្តកម្មវិធីឱ្យស្របតាមគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទតាមរយៈការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ។ ដូច្នេះ នៅឆ្នាំ ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបង្កើតនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ក្រោមឱវាទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ ស្របតាមចក្ខុវិស័យ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជានាឱ្យមាន "សហគមន៍ជនបទប្រកបដោយសុខភាព សុភមង្គល និង សុវត្ថិភាព" ហើយបានកំណត់ចក្ខុវិស័យរបស់ខ្លួនដោយជានាថា នៅឆ្នាំ ២០២៥ ប្រជាពលរដ្ឋគ្រប់រូបនៅសហគមន៍ជនបទត្រូវមានសេវាផ្គត់ផ្គង់ទឹក និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមាន អនាម័យប្រកបដោយនិរន្តរភាព ។

## I. សមិទ្ធផលសម្រេចបាន

### ១. ការពង្រឹងស្ថាប័ន និងបុគ្គលិក

- នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ មានមន្ត្រីរាជការសរុប ៦០ រូប /ស្រី ១២ រូប ដែលបានបែងចែកទៅតាមមុខងារ និងតួនាទី រួមមាន ថ្នាក់ដឹកនាំនាយកដ្ឋាន ចំនួន ១១ រូប ថ្នាក់ដឹកនាំការិយាល័យ ចំនួន ២៥ រូប និងមន្ត្រី ចំនួន ២៤ រូប ក្នុងនោះមានមន្ត្រីជាជនមានពិការភាពចំនួន ០១ រូប
- បានទទួលលិខិតចូលពីក្រៅអង្គភាព ក្រសួងស្ថាប័ន និងអង្គការដៃគូ ចំនួន ៧៩ លិខិត
- បានចេញលិខិតទៅក្រៅអង្គភាព ក្រសួងស្ថាប័ន និងអង្គការដៃគូ ចំនួន ៤៦៧ លិខិត
- បានទទួលក្របខណ្ឌមន្ត្រីរាជការថ្មី ចំនួន ០៣ រូប និងផ្ទេរភាកិច្ច ចំនួន ០១ រូប
- បានស្នើសុំដំឡើងឋានន្តរស័ក និងថ្នាក់ជូនមន្រ្តីរាជការសម្រាប់ឆ្នាំ ២០២៣ ចំនួន ១២ រូប (ស្រី ០១ រូប) និងមន្ត្រីរាជការជាជនមានពិការភាព ចំនួន ០១ រូប
- បានចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល ប្រជុំ និងកម្មវិធីផ្សេងៗ បានចំនួន ១៥២ លើក ស្មើនឹងមន្ត្រីបានចូលរួម ចំនួន ៦០ រូប (ស្រី ១២ រូប)

### ២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

- បានរៀបចំពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពឯកសារគតិយុត្តសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ
- បានបង្កើនកិច្ចសហការជាមួយអង្គការ ដៃគូអភិវឌ្ឍន៍នានា

- បានត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ទូទាំង ២៥ រាជធានីខេត្ត ។

**៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ ឆ្នាំ ២០២២**

- សាងសង់អណ្តូងស្នប់ដែលធន់នឹងការប្រែប្រួលអាកាសធាតុ សរុបចំនួន ៣០៦ អណ្តូង រួមមាន៖ រាជធានីភ្នំពេញ ១០ អណ្តូង ខេត្តកណ្តាល ០៦ អណ្តូង ព្រៃវែង ០៥ អណ្តូង ស្វាយរៀង ២៩ អណ្តូង តាកែវ ១២ អណ្តូង កំពង់ស្ពឺ ២០ អណ្តូង កំពត ០៣ អណ្តូង កែប ១៥ អណ្តូង ព្រះសីហនុ ១៦ អណ្តូង កំពង់ចាម ១៥ អណ្តូង កំពង់ឆ្នាំង ២៦ អណ្តូង កំពង់ធំ ១៣ អណ្តូង ក្រចេះ ២៤ អណ្តូង ត្បូងឃ្មុំ ១៣ អណ្តូង បន្ទាយមានជ័យ ០២ អណ្តូង បាត់ដំបង ១៦ អណ្តូង ប៉ៃលិន ០២ អណ្តូង ពោធិ៍សាត់ ១០ អណ្តូង សៀមរាប ១៥ អណ្តូង មណ្ឌលគីរី ០៦ អណ្តូង ឧត្តរមានជ័យ ១២ អណ្តូង រតនគីរី ០៤ អណ្តូង និងខេត្តស្ទឹងត្រែង ៣២ អណ្តូង
- សាងសង់/ស្តារស្រះសហគមន៍ ចំនួន ១០ ស្រះ រួមមាន៖ រាជធានីភ្នំពេញ ០១ ស្រះ ខេត្តតាកែវ ០១ ស្រះ កំពង់ស្ពឺ ០១ ស្រះ កំពត ០៣ ស្រះ កោះកុង ០១ ស្រះ ពោធិ៍សាត់ ០១ ស្រះ ឧត្តរមានជ័យ ០១ ស្រះ និងខេត្តព្រះវិហារ ០១ ស្រះ
- សាងសង់អាងត្រងទឹកភ្លៀង ចំនួន ៤៩ អាង នៅខេត្តមណ្ឌលគីរី ២០ អាង និងខេត្តរតនគីរី ២៩ អាង
- សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន ០៥ កន្លែង រួមមាន៖ ខេត្តកណ្តាល ០១ កន្លែង កោះកុង ០១ កន្លែង បន្ទាយមានជ័យ ០១ កន្លែង ប៉ៃលិន ០១ កន្លែង និងខេត្តព្រះវិហារ ០១ កន្លែង
- សាងសង់ស្ថានីយ៍ទឹកផឹកសហគមន៍ ចំនួន ០១ កន្លែង នៅខេត្តព្រៃវែង
- បានរៀបចំកិច្ចប្រជុំបច្ចេកទេស និងសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការបណ្តុះបណ្តាលបច្ចេកទេស ថែទាំ និងជួសជុលអណ្តូងទឹក ការអប់រំប្រជាពលរដ្ឋយល់ដឹងពីការប្រើប្រាស់ទឹកស្អាត ការរៀបចំផែនការសុវត្ថិភាពទឹក សរុបចំនួន ១២ លើក នៅរាជធានីភ្នំពេញ ខេត្តតាកែវ ប៉ៃលិន និងបាត់ដំបង
- បានចុះត្រួតពិនិត្យ តាមដានការអនុវត្តការងារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ២៥ រាជធានី ខេត្ត

**៤. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- បានចុះសិក្សាទីតាំងសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ចំនួន ២៥ រាជធានីខេត្ត សម្រាប់ឆ្នាំ ២០២២
- បានចុះអប់រំ ផ្សព្វផ្សាយប្រជាពលរដ្ឋតាមខ្នងផ្ទះឱ្យយល់ដឹងអំពីការប្រើប្រាស់ទឹកស្អាត ចំនួន ២៥ រាជធានីខេត្ត សម្រាប់ឆ្នាំ ២០២២

**៥. សមិទ្ធិផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

- **គម្រោង ADB**

- បានសាងសង់អណ្តូងស្នប់ ចំនួន ២៩៧ អណ្តូង នៅខេត្តបន្ទាយមានជ័យ ចំនួន ៧៦ អណ្តូង ខេត្តកំពង់ស្ពឺ ចំនួន ០៦ អណ្តូង ខេត្តសៀមរាប ចំនួន ១០០ អណ្តូង ខេត្តបាត់ដំបង ចំនួន ១១៥ អណ្តូង
- បានសាងសង់ពាង ចំនួន ២៨ ១១៩ ពាង នៅខេត្តសៀមរាប ចំនួន ៣ ៨៥២ ពាង ខេត្តកំពង់ស្ពឺ ២ ១៦៣ ពាង ខេត្តបន្ទាយមានជ័យ ចំនួន ៤ ៣២៦ ពាង ខេត្តបាត់ដំបង ចំនួន ១៥ ៣៧៤ ពាង ខេត្តប៉ៃលិន ចំនួន ៣០០ ពាង និងខេត្តពោធិ៍សាត់ ចំនួន ១ ៦២៦ ពាង ។
- បានសាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ ចំនួន ០៣ កន្លែង នៅខេត្តកំពង់ស្ពឺ ។
- បានសាងសង់ស្ថានីយស្រូបទឹកពីបរិយាកាស ចំនួន ០១ កន្លែង នៅខេត្តបន្ទាយមានជ័យ ។
- ជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ៣៥ អណ្តូង នៅឃុំចំបក់ និងស្វាយជ្រំ ស្រុកស្វាយជ្រំ ។

➢ **អង្គការយូនីសេហ្វ**

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីលទ្ធផលវាយតម្លៃ នៃការបញ្ជ្រៀបភាពធន់នឹងអាកាសធាតុនៅក្នុងកម្មវិធីទឹកស្អាត និងអនាម័យជនបទ សម្រាប់មន្ទីរអភិវឌ្ឍន៍ជនបទទាំង ២៥ រាជធានី ខេត្ត ដែលគាំទ្រថវិកាដោយអង្គការ យូនីសេហ្វ ដែលបានរៀបចំនៅខេត្តតាកែវ និងសៀមរាប
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីផែនការសុវត្ថិភាពទឹកដែលធន់ទៅនឹងអាកាសធាតុ សម្រាប់ ២៥ រាជធានី ខេត្ត នៅខេត្តក្រចេះ កំពត និងបន្ទាយមានជ័យ
- បានចុះស្រង់ទិន្នន័យប្រភពទឹកគ្រប់ប្រភេទ និងបើកវគ្គបណ្តុះបណ្តាល ស្តីពីផែនការសុវត្ថិភាពទឹកឃុំ នៅឃុំរាមអណ្តើក គោកព្រេច ឃុំព្រៃស្លឹក ស្រុកគិរីវង់ ឃុំសឹង្ហ និងរវៀង ស្រុកសំរោង ខេត្តតាកែវ
- បានចុះកែសម្រួលលើសៀវភៅផែនការសុវត្ថិភាពទឹកឃុំ សម្រាប់ឆ្នាំ ២០២០ និង ២០២១ ចំនួន ១០ ឃុំ នៅខេត្តស្វាយរៀង ចំនួន ០៤ ឃុំ ខេត្តកំពង់ស្ពឺ ចំនួន ០៦ ឃុំ
- បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីប្រូតូកូលសហគមន៍ទឹកសុវត្ថិភាព នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ
- បានចុះត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍របស់អង្គការ យូនីសេហ្វ ចំនួន ០២ កន្លែង នៅខេត្តរតនគិរី
- បានចុះត្រួតពិនិត្យសម្ភារសង្គ្រោះបន្ទាន់របស់អង្គការយូនីសេហ្វ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី
- បានបោះពុម្ពសៀវភៅគោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ ចំនួន ១ ០០០ ក្បាល។

➢ **ភាពជាដៃគូរវាងរដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីផ្គត់ផ្គង់ទឹកស្អាតនៅជនបទ** (CCCA)

- សាងសង់ស្ថានីយ៍ផលិតទឹកផឹកជនបទ នៅខេត្តចំនួន ០២ គឺខេត្តបន្ទាយមានជ័យ និងសៀមរាប
- បានពង្រៀងគោលការណ៍ណែនាំ ស្តីពីផែននការកាត់បន្ថយការខ្វះខាតទឹក ។

➢ **អង្គការ អភិវឌ្ឍន៍ជំនាញទឹកស្អាត ការសំអាត និងអនាម័យ**(WASH SDO)

- បានសហការជាមួយមន្ត្រីស្រុកអង្គស្នួល ដើម្បីបណ្តុះបណ្តាល ស្តីពីជំនាញទឹកស្អាត ការសំអាត និងអនាម័យ ដល់មន្ត្រីស្រុកអង្គស្នួល ដើម្បីឱ្យពួកគាត់ក្លាយទៅជាគ្រូបង្គោលប្រចាំស្រុក សម្រាប់បើកវគ្គបណ្តុះបណ្តាលបន្តទៅកាន់ឃុំទាំង ១០ របស់ស្រុកអង្គស្នួល ខេត្តកណ្តាល ។

➢ **អង្គការទស្សនៈពិភពលោក**

- បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការបន្សុទ្ធ និងការទុកដាក់ទឹកលក្ខណៈគ្រួសារប្រកបដោយសុវត្ថិភាព នៅស្រុកជ័យសែន ខេត្តព្រះវិហារ មានអ្នកចូលរួម ចំនួន ៣០ នាក់ ស្រី ២១ នាក់
- បានចុះបង្កើតគណៈកម្មការប្រើប្រាស់ និងថែទាំអណ្តូងស្នប់ ចំនួន ០៤ អណ្តូង នៅឃុំកក់ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

➢ **អង្គការ ActionAid Cambodia**

- បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងធនធានទឹកចម្រុះ និងទស្សនៈទាន នៃការគ្រប់គ្រង គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ នៅខេត្តកំពត កំពង់ស្ពឺ ពោធិ៍សាត់ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង និងឧត្តរមានជ័យ
- បានចុះត្រួតពិនិត្យស្ថានភាពការគ្រប់គ្រងទឹកក្រោមដីតាមអណ្តូង ចំនួន ០២ អណ្តូង នៅឃុំត្រពាំងគង ស្រុកសំរោងទង និងឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

➢ **អង្គការ អនុផលព្រៃឈើ**

- បានចុះជ្រើសរើសគណៈកម្មការ និងបង្ហាញពីតួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងស្ថានីយប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ ដែលបានជ្រើសរើស នៅភូមិខ្នារ និងក្តី ឃុំរអាង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ សរុបអ្នកចូលរួម ចំនួន ៤៩ នាក់ ស្រី ចំនួន ៣៥ នាក់ ។

➢ **អង្គការ សាម៉ារីតាន់ភឺស**

- បានអមដំណើរ ឯកឧត្តម ហាប់ អូម៉ាលី រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទដើម្បីធ្វើទស្សនកិច្ច ស្តីពីការប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ របស់អង្គការ សាម៉ារីតាន់ភឺស នៅសាលាបឋមសិក្សាបន្សាយរាក់ ចំនួន ០១ កន្លែង អនុវិទ្យាល័យបន្សាយរាក់ ចំនួន ០១ កន្លែង និងសាលាមតេយ្យសិក្សាបន្សាយរាក់ ចំនួន ០១ កន្លែង នៅភូមិបន្សាយរាក់ សង្កាត់បន្សាយរាក់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ មានអ្នកទទួលផល ចំនួន ២៥៦ គ្រួសារ និងសិស្សានុសិស្ស ចំនួន ៣៦២ នាក់ ស្រី ២១៤ នាក់ ។

➢ **អង្គការ ទឹកស្អាត ១០០១**

- បានសាងសង់ស្ថានីយផលិតទឹកផឹកសហគមន៍ ចំនួន ៣៦ ស្ថានីយ នៅខេត្តប៉ៃលិន ចំនួន ០៣ ស្ថានីយ ខេត្តតាកែវ ចំនួន ០២ ស្ថានីយ ខេត្តកណ្តាល ចំនួន ២៩ ស្ថានីយ ក្នុងនោះ ស្ថានីយ ចំនួន ២១ ស្ថានីយកំពុងដំណើការ និងស្ថានីយ ចំនួន ០៨ ស្ថានីយផ្សេងទៀតមិនមានដំណើការ ដោយមូលហេតុប្រជាជនមិនបានចូលរួមគាំទ្រ និងមិនមានប្រភពទឹកគ្រប់គ្រាន់ ។

➢ **ថវិការបស់ថ្នាក់ខេត្ត**

- **ខេត្តប៉ៃលិន**

- បានសាងសង់អាងត្រងទឹកភ្លៀងចំណុះ ៤ ម៉ែត្រគូប ចំនួន ២៥ អាង
- បានសាងសង់អណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ០២ អណ្តូង ។
- **ខេត្តកំពង់ចាម**
- បានស្តាប្រឡាយ ប្រវែង ៣ ៥០០ ម៉ែត្រ នៅភូមិកុមារ និងត្រប់ ឃុំសំពង ស្រុកជើងព្រៃ ។
- **ខេត្តត្បូងឃ្មុំ**
- បានស្តារស្រះ ចំនួន ០៥ ស្រះ នៅស្រុកត្បូងឃ្មុំ ស្រុកពញាក្រែក ស្រុកអូរាំងឪ ។
- **ខេត្តពោធិ៍សាត់**
- បានជួសជុលអណ្តូងស្នប់ ចំនួន ២៦ អណ្តូង នៅឃុំផ្ទះរុង ស្រុកតាលោសែនជ័យ ។

II. **បញ្ហាប្រឈម**

- សកម្មភាពការងារមួយចំនួន ដូចជា ការបណ្តុះបណ្តាលផែនការសុវត្ថិភាពទឹកជនបទ ការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដល់សហគមន៍ជនបទ មិនអាចអនុវត្តទៅបានតាមការគ្រោង ទុក ដោយសារតែការរាតត្បាតពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ទើបតែបញ្ចប់ ប៉ុន្តែមេរោគនៃជំងឺកូវីដ-១៩ ប្រភេទថ្មី នៅតែបន្តរីរាលដាលក្នុងសហគមន៍នៅឡើយ
- អត្រាគ្របដណ្តប់ទឹកនៅតាមតំបន់មួយចំនួននៅមានភាគរយទាបនៅឡើយ
- ការចូលរួមរបស់សហគមន៍ និងកិច្ចសហការរបស់អង្គការ ដៃគូអភិវឌ្ឍន៍នានាលើវិស័យផ្គត់ផ្គង់ទឹកនៅមានកម្រិត
- បញ្ហាបម្រែបម្រួលអាកាសធាតុនៅតែកើតមានជារឿយៗ
- ការចូលរួមរបស់សហគមន៍ និងកិច្ចសហការរបស់អង្គការ ដៃគូអភិវឌ្ឍន៍នានាលើវិស័យផ្គត់ផ្គង់ទឹកនៅមានកម្រិត
- អណ្តូងមួយចំនួនត្រូវបានរីងស្ងួត និងខូចខាតដោយសារតែការប្រែប្រួលអាកាសធាតុ

III. **ទិសដៅការងារឆ្នាំ ២០២៣**

**១. ការពង្រឹងស្ថាប័ន និងបុគ្គលិក**

- បន្តពង្រឹងការងាររដ្ឋបាល
- បន្តពង្រឹងការងារបណ្តុះបណ្តាល និងអប់រំផ្សព្វផ្សាយដល់មន្ត្រីបច្ចេកទេសរបស់នាយកដ្ឋាន និងមន្ទីរអភិវឌ្ឍន៍ទាំងអស់
- បន្តយកចិត្តទុកដាក់ និងលើកទឹកចិត្តដល់ជនមានពិការភាពនៅក្នុងនាយកដ្ឋាន

**២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត**

- បន្តរៀបចំ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពឯកសារគតិយុត្តសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ
- បន្តបង្កើនកិច្ចសហការជាមួយអង្គការ ដៃគូអភិវឌ្ឍន៍នានា
- បន្តចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ទូទាំង ២៥ រាជធានីខេត្ត ។

**៣. ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ ឆ្នាំ ២០២២**

- រៀបចំសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ សម្រាប់ថវិកាកម្មវិធីឆ្នាំ ២០២៣ រួមមាន អណ្តូង ចំនួន ៣៤៩ អណ្តូង ស្រះសហគមន៍ ចំនួន ០៦ ស្រះ សាងសង់អាងត្រងទឹកភ្លៀងចំណុះ ៤ ម៉ែត្រគូប ចំនួន ៣៨ អាង សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ ចំនួន ០៤ កន្លែង សាងសង់ស្ថានីយ៍ផលិតទឹកផឹកសហគមន៍ ចំនួន ០១ ស្ថានីយ៍
- រៀបចំកម្មវិធីអង្គវិបស្សនា ស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ក្នុងខែកុម្ភៈ ឆ្នាំ ២០២៣ នៅខេត្តស្ទឹងត្រែង

**៤. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- បន្តចុះសិក្សាទីតាំងសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ចំនួន ២៥ រាជធានីខេត្ត សម្រាប់ឆ្នាំ ២០២២
- បន្តចុះអប់រំ ផ្សព្វផ្សាយប្រជាពលរដ្ឋតាមខ្នងផ្ទះឱ្យយល់ដឹងអំពីការប្រើប្រាស់ទឹកស្អាត ចំនួន ២៥ រាជធានីខេត្ត សម្រាប់ឆ្នាំ ២០២២

**៥. សមិទ្ធិផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

- បន្តការងារសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូរ អភិវឌ្ឍន៍
- បន្តការងារសហប្រតិបត្តិការជាមួយគម្រោងដៃគូរអន្តរជាតិ

## សេចក្តីសន្និដ្ឋាន

ការអនុវត្តសកម្មភាពផ្គត់ផ្គង់ទឹកស្អាតជនបទ ដែលរួមមាន ការសាងសង់ និងជួសជុលអណ្តូងស្នប់ ពាងយក្ស ធុងចម្រោះ អាងត្រងទឹកភ្លៀង អាងចម្រោះជាតិដែក ស្រះសហគមន៍ ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ ប្រព័ន្ធស្រោចស្រព និងថាមពលខ្នាតតូច...ជាដើម ។ល។ គឺជាការរួមចំណែកក្នុងយុទ្ធនាការ នៃការជួយកាត់បន្ថយភាពក្រីក្រ និងបានឆ្លើយតបទៅនឹងគោលនយោបាយជាតិ គោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ ជាពិសេស គឺបានជួយដល់តម្រូវការ នៃការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ ។ ម្យ៉ាងវិញទៀត នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ក៏ជាសេនាធិការមួយដ៏សំខាន់ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការដើរតួនាទីជាអ្នកសម្របសម្រួលការអនុវត្តសកម្មភាព ដើម្បីផ្តល់សេវាកម្មទឹកស្អាតជូនដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន គឺក្នុងគោលបំណងដើម្បីចូលរួមចំណែកក្នុងការផ្លាស់ប្តូរ និងអភិវឌ្ឍន៍សហគមន៍ប្រកបដោយចីរភាព។ ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាល ជាពិសេស ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទដែលមាន **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ជាប្រមុខបានធ្វើឱ្យការងារផ្គត់ផ្គង់ទឹកជនបទមានការវិវឌ្ឍរីកចម្រើនខ្លាំងដោយប្រជាពលរដ្ឋទទួលបាននូវការអប់រំ ស្តីពីការប្រើប្រាស់ទឹកស្អាត និងអនាម័យជនបទ ។